ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៧ លេខ ៨៨ សប្តាហ៍ទី ៤ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៧

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

348.033
CAM

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច សារាចរ ប្រកាស

មាតិកា

I~ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៩-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៨៥ ស្ដីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ នៃក្រសួងពាណិជ្ជកម្ម ចំនួន ០៤ រូប ៥៤១៧

២០-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៨៧ ស្ដីពីការប្រគល់ភារកិច្ចជូនឯកឧត្តម **ម៉ុន ចំន្ទវណ្ណៈ** ឱ្យបំពេញមុខងារជាអគ្គាធិការ នៃក្រសួងអភិវឌ្ឍន៍ជនបទ ៥៤១៩

២១-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៨៨ ស្ដីពីការតែងតាំងឯកឧត្តម **យឹម សាខ** ជាទីប្រឹក្សាផ្ទាល់សម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ៥៤២០

26-11-2007 -KRET NS/KRT/1107/591 NOMMONS Monsieur Robért Malengreau Grang-Officier de l'Ordre Royal du Cambodge, en témoignage de Notre très haute considération. ៥៤២១

26-11-2007 -KRET NS/KRT/1107/592 NOMMONS Monsieur Michel Lombet Commandeur de l'Ordre Royal du Sahamétrei.
- Monsieur Pierre Swennen Commandeur de l'Ordre Royal du Monisaraphon.
- Monsieur Guy Lebrun Officier de l'Ordre Royal du Monisaraphon. ៥៤២២

II~ក្រុមប្រឹក្សាធម្មនុញ្ញ

១~សេចក្ដីសំរេច

២៧-១១-២០០៧ -សេចក្ដីសំរេច លេខ ០៩៤/០០៥/២០០៧ កបធ.ច ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ៥៤២៣

២១-១១-២០០៧ -សេចក្ដីសំរេច លេខ ០៩៥/០០៦/២០០៧ កបធ.ច ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ៥៤២៨

III~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

២៨-១១-២០០៧ -អនុក្រឹត្យ លេខ ១៧៨ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៥៤៣៣

២៨-១១-២០០៧ -អនុក្រឹត្យ លេខ ១៧៩ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៥៤៣៥

២៨-១១-២០០៧ -អនុក្រឹត្យ លេខ ៩៣៥ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥៤៣៧

២៨-១១-២០០៧ -អនុក្រឹត្យ លេខ ៥៣៦ អនក្រ.បក ស្តីពីការជូនមេដាយការងារ ៥៤៣៨

២៨-១១-២០០៧ -អនុក្រឹត្យ លេខ ៥៣៧ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៤៤០

២៨-១១-២០០៧ -អនុក្រឹត្យ លេខ ៥៣៨ អនក្រ.បក ស្តីពីការជូនមេដាយសហមេត្រី ៥៤៤១

២៨-១១-២០០៧ -អនុក្រឹត្យ លេខ ៥៣៩ អនក្រ.បក ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៤៤២

២៨-១១-២០០៧ -អនុក្រឹត្យ លេខ ៥៤០ អនក្រ.បក ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៤៤៣

២៩-១១-២០០៧ -អនុក្រឹត្យ លេខ ៥៤១ អនក្រ.បក ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃព្រះរាជាណាចក្រកម្ពុជា ៥៤៤៤

៣០-១១-២០០៧ -អនុក្រឹត្យ លេខ ៥៤២ អនក្រ.បក ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៤៤៧

២_សេចក្តីសំរេច

២៩-១១-២០០៧ -សេចក្តីសំរេចលេខ ៦៣ សសរ ស្តីពីការតែងតាំងសមាសភាពជាក់ស្តែងរបស់អាជ្ញាធរអាងទន្លេសាប ៥៤៤៨

IV_ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សារាចរណែនាំ

២២-១១-២០០៧ -សារាចរណែនាំ លេខ ០០៦ សហវ ស្តីពីការរៀបចំផែនការលទ្ធកម្ម ឆ្នាំ ២០០៨ និងឆ្នាំបន្តបន្ទាប់ ៥៤៥១

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៨៦ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីហ៊ីម៉ិច** ៥៤៥៩

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៨៨ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វ្រីន ហ្វាម៉ា** ៥៤៦១

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៨៩ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេនើជី_សូឡារី** ៥៤៦៣

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៩០ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាន់វ៉ាយ ឆេហ្វើ អេន រ៉ិនតើមេនម៉េន** ៥៤៦៥

គ

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៩១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេនឌ្រី តែវើជាយ អេន្ថរ** ៩៤៦៧

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៩៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្លូបឹល សឺកសេស អ៊ីនធើណេសិនណាល** ៩៤៦៩

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាយ ខាំ អ៊ីមផត & អិចផត ខូ អិលធីឌី** ៩៤៧១

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៩៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡៃថ៍ អិចប្រេស ឡូជីស្ទីក** ៩៤៧៣

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២០៦ ពណ.នតក ស្តីពីការអនុញ្ញាតជាគោលការណ៍អោយបង្កើត ការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន **គីសាន ឆេឈីខម** ប្រចាំរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានចុះបញ្ជី នៅប្រទេសកូរ៉េ ៩៤៧៥

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេន្ថរ គ្រូត អយឃើ ខេមីខល គ្រុប** ៩៤៧៦

២២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ សាខាក្រុមហ៊ុន **ឌៀន ខាន់ ហ្វាម៉ាស៊ូធីខល** ៩៤៧៨

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៨៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានផ្លូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ
ខេមរាជនា សម្ភូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការ នៃក្រសួងពាណិជ្ជកម្ម ដូចមានរាយនាមខាងក្រោម ៖

១. ឯកឧត្តម **សួស វណ្ណា** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន

២. ឯកឧត្តម **សម សម្បត្តិ** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

៣. ឯកឧត្តម **សុខ សុភ័ក្ត្រ** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ

ROYAUME DU CAMBODGE

៤. ឯកឧត្តម ពេជ ឫទ្ធី ជាអគ្គនាយក នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត/១១០៧/៦១៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ:៥៥១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ចិនកេន

នស/រកត/១១០៧/៥៨៧

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **ម៉ិន ច័ន្ទវណ្ណៈ** ឱ្យបំពេញមុខងារជាអគ្គាធិការនៃក្រសួងអភិវឌ្ឍន៍ជនបទ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពរល.០៧១១.៦១៦

លេខ:៥៥០ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី/រាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៧

[illegible] ម៉ែងកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៨៩

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្ដីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងឯកឧត្ដម យឹម លាង ជាទីប្រឹក្សាផ្ទាល់សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្ដម សីហមុនី

៣រល.០៧១១.៦១៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ:៥៤៩ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

KRET

NS / KRT / 1107 / 591

Nous

Preah Karuna Preah Bat Samdech

Preah Boromneath Norodom Sihamoni

Roi du Cambodge

NOMMONS

Monsieur Robert Malengreau

Grand-Officier de l'Ordre Royal du Cambodge,

en témoignage de Notre très haute considération.

Norodom Sihamoni

៣.ព.០៧២១.៦២០

Fait au Palais Royal à Phnom Penh, le 26 Novembre 2007

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

លេខ [illegible] ព.ចច

ភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៧

សម្តេចចៅហ្វាវាំង វរៀងជ័យ អធិបតីស្រីង្គារ

ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីព្រះបរមរាជវាំង,

[signature]

គង់ សំអុល,

ROYAUME ... LE MINISTÈRE DU PALAIS ROYAL

KRET

NS / KRT / 1107 / 592

Nous
Preah Karuna Preah Bat Samdech
Preah Boromneath Norodom Sihamoni
Roi du Cambodge

NOMMONS

Monsieur Michel Lombet
Commandeur de l'Ordre Royal du Sahamétrei.

Monsieur Pierre Swennen
Commandeur de l'Ordre Royal du Monisaraphon.

Monsieur Guy Lebrun
Officier de l'Ordre Royal du Monisaraphon.

Norodom Sihamoni

៣រល. ០៧១១. ៦២១

Fait au Palais Royal à Phnom Penh, le 26 Novembre 2007

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ...៥៥៤/០៧... រ.ចប
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ...វិច្ឆិកា... ឆ្នាំ ២០០៧
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

MINISTRE DU PALAIS

គង់ សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ១៣៤/០០៦/២០០៧

ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧

សេចក្តីសម្រេច

លេខ : ០៩៤/០០៥/២០០៧ កបធ.ច

ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ដែលឱ្យឃុំព្រែកជ្រៃរក្សាឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ចំនួន ១.៣៣១ នាក់ និង នៅឃុំសំពៅពូនរក្សាឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ចំនួន ៧០២ នាក់
- បានឃើញពាក្យបណ្តឹងរបស់លោក ឡុង លឹមមិរា ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ ប្តឹងទាមទារសុំឱ្យលុបឈ្មោះជនជាតិវៀតណាម ចំនួន ២.០៣៣ នាក់ និង សុំបដិសេធសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះហត្ថលេខាដោយឯកឧត្តម អ៊ឹម សូស្តី នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០២ (តាមពិតគឺឆ្នាំ២០០៧) ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង ១០:៤៥ នាទី
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ របស់ឯកឧត្តម សម រង្ស៊ី ប្រធានគណបក្សសម រង្ស៊ី ផ្ទេរសិទ្ធិជូនលោក ឡុង លឹមមិរា ជាតំណាងគណបក្សសមរង្ស៊ី ដើម្បីដាក់ពាក្យបណ្តឹង និង ចូលរួមសវនាការជំនួសនៅក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៣៨/០៧ គ.ជ.ប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០០៧ ឧទ្ទេសនាមសមាជិក និងមន្ត្រីនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចូលរួមក្នុងសវនាការជំនុំជម្រះជាសាធារណៈនៅក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុស៊ើបអង្កេតនៅឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧
- បានឃើញកំណត់ហេតុស៊ើបអង្កេតនៅឃុំព្រែកជ្រៃ ស្រុកកោះធំ ខេត្តកណ្តាល ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧
- បានឃើញកំណត់ហេតុឆ្លើយចំភ្លឺរបស់លោក ឡុង លឹមមិរា កាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០៧
- បានឃើញកំណត់ហេតុឆ្លើយចំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា បណ្តឹងរបស់លោក ឡុង លឹមមិរា ជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលបិទផ្សាយជាសាធារណៈបញ្ជីបោះឆ្នោតដំបូង ។ យោងតាមមាត្រា ៦៤ ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី៣ មាត្រា ២៦ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

បណ្តឹងរបស់លោក **ឡុង លឹមហ៊ា** បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកមកពិនិត្យបាន ទោះបីមានការខ្វះខាតនៅក្នុងកម្មវត្ថុនៃពាក្យបណ្តឹង ដោយដាក់កាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០២ តាមពិតគឺ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧

-យល់ឃើញថា នៅក្នុងពាក្យបណ្តឹង ក៏ដូចជាការឆ្លើយបំភ្លឺនៅពេលសាកសួរចម្លើយ លោក **ឡុង លឹមហ៊ា** បានទាមទារសុំឱ្យលុបឈ្មោះជនជាតិវៀតណាម ចំនួន ២.០៣៣ នាក់ ដោយសំអាងថា អ្នកទាំងនោះ ជាជនអន្តោប្រវេសន៍ខុសច្បាប់ ដែលមករស់នៅប្រទេសកម្ពុជា ដោយគ្មានច្បាប់អនុញ្ញាត ពុំមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ គ្មានសៀវភៅស្នាក់នៅ មានតែប័ណ្ណស្នាក់នៅតែមួយគត់ ហើយជនជាតិវៀតណាមមួយចំនួនរស់នៅលើដីវៀតណាម នៅពេលបោះឆ្នោតពួកគេមកចូលរួមបោះឆ្នោត ។ នៅក្នុងពេលសវនាការជំនុំជម្រះ លោក **ឡុង លឹមហ៊ា** ឆ្លើយបញ្ជាក់ថា ពុំមានភស្តុតាងជាលាយលក្ខអក្សរទេ ប៉ុន្តែគ្រាន់តែសង្កេតផ្ទាល់ឃើញថា ជនទាំងនោះ ជាជនវៀតណាម និយាយភាសាវៀតណាម របៀបរស់នៅជាវៀតណាម

-យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះនិងការឆ្លើយបំភ្លឺនៅពេលសាកសួរចម្លើយ ឯកឧត្តម **មាន សទិ** ឯកឧត្តម **ម៉ៅ សុផារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបញ្ជាក់ថា ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រេចបដិសេធពាក្យបណ្តឹងរបស់លោក **ឡុង លឹមហ៊ា** ហើយរក្សាទុកឈ្មោះជនទាំង ២.០៣៣ នាក់ គឺសំអាងលើមូលហេតុបី :

១- អ្នកប្តឹងគ្មានភស្តុតាង ។ អ្នកប្តឹងមិនមានភស្តុតាង តាមការតម្រូវរបស់មាត្រា ៦៤ ថ្មី នៃច្បាប់បោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ

២- មេឃុំ និង មេប៉ុស្តិ៍ បានបញ្ជាក់ថា នៅពេលធ្វើបញ្ជីស្រង់ឈ្មោះជនអន្តោប្រវេសន៍បញ្ជូនមកក្រសួងមហាផ្ទៃ ជនទាំង ២.០៣៣ នាក់នេះ ពុំមានឈ្មោះនៅក្នុងបញ្ជីជនអន្តោ-ប្រវេសន៍ទេ ។

៣- សៀវភៅស្នាក់នៅរបស់អ្នកដែលគេត្រូវប្តឹងបានបញ្ជាក់ថា មានសញ្ជាតិខ្មែរ ។ អ្នកទាំងនោះមានទីលំនៅជាយូរមកហើយ និង មានដីធ្វើស្រែ ចំការ ។

-យល់ឃើញថា លោក **ឡុង លឹមហ៊ា** ពុំមានភស្តុតាងដើម្បីសុំលុបឈ្មោះទាំង ២.០៣៣ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង ចំណែកឯការអះអាងរបស់សាមីខ្លួនពុំមានមូលដ្ឋានគតិយុត្តិឡើយ

-យល់ឃើញថា ការលើកឡើងរបស់ឯកឧត្តម **មាន សទិ** និង ឯកឧត្តម **ម៉ៅ សុផារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលចង្អុលទៅលើមាត្រា ៦៤ ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មានទម្ងន់ខាងផ្លូវច្បាប់ ដែលអាចយកជាការបាន

-យល់ឃើញថា តាមការស្រាវជ្រាវរបស់តំណាងក្រុមប្រឹក្សាធម្មនុញ្ញ នៅឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ប្រជាពលរដ្ឋ ចំនួន ១.៣៣១ នាក់ និង នៅឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ប្រជាពលរដ្ឋ ចំនួន ៧០២ នាក់ ដែលលោក ឡុង លីមហ៊ា ប្តឹងទាមទារសុំលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដំបូង សុទ្ធតែមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ស្របតាមមាត្រា ៩៤ ថ្មី ចំណុច "គ" នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-យល់ឃើញថា បញ្ជីឈ្មោះដែលលោក ឡុង លីមហ៊ា ប្តឹងទាមទារសុំលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដំបូង នៅឃុំព្រែកថ្មី និង នៅឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល តាមការស៊ើបសួរដល់មូលដ្ឋានឃុំព្រែកថ្មី និង ឃុំសំពៅពូន របស់តំណាងក្រុមប្រឹក្សាធម្មនុញ្ញ និង តាមការផ្ទៀងផ្ទាត់របស់នាយកដ្ឋានជំនាញ ដោយពិនិត្យទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ កាលពីឆ្នាំ២០០៦ មានការអះអាងប្រហាក់ប្រហែលគ្នាថា គឺមានឈ្មោះមួយចំនួនធំ ឬ ស្ទើរតែទាំងអស់ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះ ដែលលោក នួន រិទ្ធី បានដាក់ពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ នៅឃុំព្រែកថ្មី និង នៅឃុំសំពៅពូន មានពាក្យបណ្តឹងរបស់លោក ទីឈរា សាគុណ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកាឆ្នាំ ២០០៦ ដែលក្រុមប្រឹក្សាធម្មនុញ្ញ ធ្លាប់បានពិនិត្យ និង សម្រេចរួចហើយ គឺ÷

- ករណីឃុំព្រែកថ្មី តាមសេចក្តីសម្រេចលេខ ០៨៦/០១៣/២០០៦ កបធ.ច ចុះថ្ងៃទី ២៥ ខែវិច្ឆិកាឆ្នាំ២០០៦ គឺតម្កល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។
- ករណីនៅឃុំសំពៅពូន តាមសេចក្តីសម្រេចលេខ ០៨៤/០១១/២០០៦កបធ.ច ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៦ គឺតម្កល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប៉ុន្តែតម្រូវឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លុបឈ្មោះប្រជាពល-រដ្ឋ ចំនួន ០២នាក់ដែលបានស្លាប់ និង ប្រជាពលរដ្ឋ ចំនួន ២៦ នាក់ បានផ្លាស់ប្តូរទីលំនៅនៅឃុំចុងឃ្នៀស ស្រុកសៀមរាប ខេត្តសៀមរាប ក្នុងចំណោមពលរដ្ឋដែលសុំលុបឈ្មោះចំនួន ៧៦៣ នាក់ ។ ចំណែកករណីនៅឃុំសំពៅពូន រក្សាទុកដដែល ។

-យល់ឃើញថា ការបញ្ជាក់អំពីធាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ៕/.

សម្រេច

មាត្រា ១. ~ ទទួលពាក្យបណ្តឹងរបស់លោក ឡុង លឹមហ៊ា ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

មាត្រា ២. ~ តម្កល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ដែលសម្រេច ៖

១-ឃុំព្រែកជ្រៃ រក្សាឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ចំនួន ១.៣៣១ នាក់

២-ឃុំសំពៅពូន រក្សាឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ចំនួន ៧០២ នាក់

ទុកជាបានការពេញទាំងមូល ។

មាត្រា ៣. ~ សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។ ស/ប

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ជ.ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ១៣៥/០០៧/២០០៧

ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧

សេចក្តីសម្រេច

លេខ : ០៩៥/០០៦/២០០៧ កបធ.ច

ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ដែលបដិសេធសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់គីឡូម៉ែត្រលេខ៦ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ចោលជាអាសារបង់ និង លុបឈ្មោះអ្នកបោះឆ្នោត ចំនួន ៣.២៤៤នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង សង្កាត់គីឡូម៉ែត្រលេខ៦
- បានឃើញពាក្យបណ្ដឹងរបស់លោក **លី សុទិដ្ឋា** ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ប្ដឹងតវ៉ាឱ្យរក្សាឈ្មោះប្រជាពលរដ្ឋខ្មែរ ចំនួន ៣.២៤៤ នាក់ ក្នុងបញ្ជីបោះឆ្នោតដំបូងនៃសង្កាត់ គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង ១៦:៣៥ នាទី
- បានឃើញលិខិតប្រគល់សិទ្ធិជូនលោក **លី សុទិដ្ឋា** ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ របស់ប្រជាពលរដ្ឋ ចំនួន ១៤ នាក់ ដែលអះអាងថា ជាតំណាងប្រជាពលរដ្ឋ ចំនួន ៣.២៤៤ នាក់ ហើយដែលត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រេចលុបឈ្មោះ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៣៩/០៧ គ.ជ.ប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០០៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមសមាជិក និង មន្ត្រីនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចូលរួមក្នុងសវនាការជំនុំជម្រះជាសាធារណៈនៅក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុចុះស៊ើបអង្កេតនៅសង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០៧
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **លី សុទិដ្ឋា** កាលពីថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០០៧
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍
ក្រោយពីបានស្ដាប់ចម្លើយរបស់គូភាគី សាក្សី និង អ្នកពាក់ព័ន្ធក្នុងការបោះឆ្នោត
ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា បណ្ដឹងរបស់លោក **លី សុទិដ្ឋា** ជាបណ្ដឹងស្ថិតនៅក្នុងដំណាក់កាលបិទផ្សាយជាសាធារណៈបញ្ជីបោះឆ្នោតដំបូង ។ យោងតាមមាត្រា ៦៤ ថ្មីនៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី៣ មាត្រា ២៦ ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្ដឹងរបស់លោក **លី សុទិដ្ឋា** បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា នៅក្នុងពាក្យបណ្ដឹង ក៏ដូចជាការឆ្លើយបំភ្លឺនៅពេលសាកសួរយកចម្លើយ លោក **លី សុទិដ្ឋា** បានលើកឡើងថា ÷

១-ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំបានឈរលើមូលដ្ឋានភស្តុតាងច្បាស់លាស់ឡើយ គឺគ្រាន់តែសម្រេចតាមបញ្ជីរាយនាមដែលស្រង់ដោយមេភូមិ និង ការអះអាងរបស់ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់

២-ការស្រង់បញ្ជីរបស់មេភូមិ និង ការអះអាងរបស់ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ផ្ទុយនឹងសេចក្តីណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពីព្រោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការសម្អាតបញ្ជី និងការចុះឈ្មោះបោះឆ្នោត មិនបានប្រតិភូកម្មឱ្យប្រធានភូមិ ឬ ប្រធានប៉ុស្តិ៍ទេ ។

-យល់ឃើញថា នៅពេលសវនាការជំនុំជម្រះលោក **លី សុទិដ្ឋា** សុំឱ្យរក្សាទុកឈ្មោះប្រជាពលរដ្ឋទាំង ៣.២៤៤ នាក់ ក្នុងបញ្ជីបោះឆ្នោតវិញ

-យល់ឃើញថា នៅពេលសាកសួរយកចម្លើយលោក **លី សុទិដ្ឋា** មិនអាចកំណត់បានថា ប្រជាពលរដ្ឋទាំង ៣.២៤៤នាក់ ពិតជាមានទីលំនៅអចិន្ត្រៃយ៍នៅសង្កាត់គីឡូម៉ែត្រលេខ៦ ។ លោក **លី សុទិដ្ឋា** មិនអាចកំណត់បានថា ប្រជាពលរដ្ឋដែលមានទីលំនៅអចិន្ត្រៃយ៍មានប៉ុន្មានភាគរយ ឬ ប្រជាពលរដ្ឋប៉ុន្មានភាគរយ ដែលពុំមានទីលំនៅជាអចិន្ត្រៃយ៍ ។ លោកបានបញ្ជាក់ថា គឺមានតែអាជ្ញាធរមូលដ្ឋានអាចបញ្ជាក់ពីបញ្ហានេះបាន

-យល់ឃើញថា ក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ បានសំណូមពរឱ្យលោក **លី សុទិដ្ឋា** សហការជាមួយតំណាងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីចុះទៅបណ្តាភូមិទាំង ០៣ ក្នុងសង្កាត់គីឡូម៉ែត្រលេខ៦ ដើម្បីអង្កេតតាមវិធី Random Check ទៅលើប្រជាពលរដ្ឋមួយចំនួនក្នុងចំណោមប្រជាពលរដ្ឋ ចំនួន ៣.២៤៤ នាក់ តាមតំណាងរបស់ក្រុមប្រឹក្សាធម្មនុញ្ញចង្អុលឈ្មោះ ប៉ុន្តែលោក **លី សុទិដ្ឋា** បានអះអាងថា អាចជូនតំណាងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទៅជួបបានតែមនុស្ស ចំនួន ១៤ នាក់ ដែលបានផ្ទេរសិទ្ធិឱ្យលោកធ្វើជាតំណាង និង ឈ្មោះចំនួន ៣៦ នាក់ ទៀតតែប៉ុណ្ណោះ

-យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះ លោក **សុខ សម្បត្តិ** ចៅសង្កាត់គីឡូម៉ែត្រលេខ៦ និងជាសាក្សីរបស់លោក **លី សុទិដ្ឋា** បានបញ្ជាក់ថា ខ្ញុំសុំនិយាយតែពីរឿងជាក់ស្តែងដែលមានឯកសារភ្ជាប់មកជាមួយ ឈ្មោះដែលមានក្នុងបញ្ជីថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០៧ តែពេលវេលាមិនអាចឱ្យខ្ញុំស្រាវជ្រាវបាន នៅសង្កាត់ខ្ញុំពុំមានតែប៉ុណ្ណឹងទេ មានលើសពីហ្នឹងទៅទៀត

-យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះ លោក **សុខ ឃឹម** ចៅសង្កាត់រងគីឡូម៉ែត្រលេខ៦ និងជាសាក្សីរបស់លោក **លី សុទិដ្ឋា** បានបញ្ជាក់ថា ខ្ញុំចូលមកធ្វើសាក្សីនេះ ដើម្បីការពារទុកឈ្មោះប្រជាពលរដ្ឋទាំង ៣.២៤៤ នាក់ ទុកក្នុងបញ្ជីបោះឆ្នោត

-យល់ឃើញថា ការឆ្លើយបំភ្លឺនៅពេលសាកសួរចម្លើយ ក៏ដូចជានៅក្នុងសវនាការជំនុំជម្រះ ឯកឧត្តម **ឯម សុផាន** ឯកឧត្តម **ឃ្លោក ម៉ុតឌី** និង លោក **តែប ផល្លា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបញ្ជាក់ថា ÷

១-ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺមានមូលដ្ឋានច្បាស់លាស់ក្នុងការកាត់សេចក្តី ពីព្រោះការស្នាក់នៅរបស់ប្រជាពលរដ្ឋ · គឺជាសមត្ថកិច្ចរបស់នគរបាលប៉ុស្តិ៍ ហើយការបញ្ជាក់របស់ប៉ូលីសប៉ុស្តិ៍បង្ហាញថា ពលរដ្ឋទាំងនោះពុំបានរស់នៅក្នុងសង្កាត់គីឡូម៉ែត្រលេខ៦ ទេ ។ ម្យ៉ាងវិញទៀត ក្នុងសវនាការនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លោកចៅសង្កាត់គីឡូម៉ែត្រលេខ៦ គ្មានលើកភស្តុតាងណាមួយជូនក្រុមប្រឹក្សាជំនុំជម្រះនៃគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត លោកចៅសង្កាត់គីឡូម៉ែត្រលេខ៦ សម្អាងត្រឹមថា នីតិវិធីឈ្មោះនៅក្នុងបញ្ជីចុងក្រោយមិនអាចលុបបាន ។ ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សួរលោកចៅសង្កាត់គីឡូម៉ែត្រលេខ៦ ថា មានបានចុះទៅធ្វើការអង្កេតទេ លោកចៅសង្កាត់គីឡូម៉ែត្រលេខ៦ បានឆ្លើយថា អត់បានចុះទៅអង្កេតទេ ។ តាមការស្រាវជ្រាវរបស់ក្រុមការងារទៅលើឈ្មោះពលរដ្ឋ ២០ នាក់ តាមវិធី Random Check ដើម្បីឱ្យច្បាស់ថា ការរាយការណ៍របស់ប៉ូលីសប៉ុស្តិ៍ត្រឹមត្រូវឬទេ ? ជាលទ្ធផលបានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋ ២០ នាក់នេះ ពុំមានទីលំនៅក្នុងសង្កាត់គីឡូម៉ែត្រលេខ៦ ប្រាកដមែន ។

២-ចំពោះបញ្ជីរាយនាមដែលស្រង់ដោយលោកមេភូមិ និង មានហត្ថលេខារបស់លោកមេភូមិ លោកអនុប្រធានភូមិ និង លោកនាយប៉ុស្តិ៍នគរបាលរដ្ឋបាល គីឡូម៉ែត្រលេខ៦ គឺជាភស្តុតាងដែលដើមចោទផ្តល់ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមការតម្រូវរបស់មាត្រា ៦៤ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ អំពីបញ្ហាប្រតិភូកម្ម គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពិតជាបានប្រតិភូកម្មដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺនៅក្នុងដំណាក់កាលធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ដំណាក់កាលចុះឈ្មោះបោះឆ្នោត នៅពេលធ្វើការងារនេះចប់ហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបិទបញ្ជីបោះឆ្នោតដំបូងនេះ ដើម្បីឱ្យគេប្តឹងតវ៉ា ឬ ប្តឹងជំទាស់ ។ យោងតាមមាត្រា ៦៤ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ លោកនាយប៉ុស្តិ៍នគរបាលរដ្ឋបាលគីឡូម៉ែត្រលេខ៦ ដែលជាអ្នកធ្វើសៀវភៅស្នាក់នៅដឹងច្បាស់ជាងគេអំពីការស្នាក់នៅរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានសង្កាត់គីឡូម៉ែត្រលេខ៦

-យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះ លោក **ម៉ាង ស៊ុមអេង** មេភូមិស្ពានខ្ពស់ ដែលជាអ្នកពាក់ព័ន្ធក្នុងការបោះឆ្នោតបានបំភ្លឺថា ចៅសង្កាត់បានអញ្ជើញប្រធានភូមិឱ្យធ្វើបញ្ជី ដើម្បីត្រៀមសម្អាតបញ្ជី ។ ប្រធានភូមិបានធ្វើ ហើយក៏បញ្ជូនទៅសង្កាត់ ប៉ុន្តែចៅសង្កាត់មិនឯកភាព

-យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះ លោក **អ៊ុង ឫទ្ធិ** នាយប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់គីឡូម៉ែត្រលេខ៦ ដែលជាអ្នកពាក់ព័ន្ធក្នុងការបោះឆ្នោតបានបំភ្លឺថា ប្រជាពលរដ្ឋទាំង ៣.២៤៤ នាក់ ដែលប្រធានភូមិបានធ្វើ គឺអនុវត្តតាមការណែនាំរបស់គណៈកម្មការធិការជាតិរៀបចំការបោះឆ្នោត ដើម្បីសម្អាតបញ្ជី ដោយសុំឱ្យនាយប៉ុស្តិ៍នគរបាលរដ្ឋបាលជួយសហការក្នុងការពិនិត្យ ខ្ញុំបានចាត់តាំង

នគរបាលឱ្យចុះត្រួតពិនិត្យសៀវភៅស្នាក់នៅក១ ហើយបានបញ្ជាក់ថា មិនមានមនុស្សនៅក្នុងមូលដ្ឋាននោះទេ

- យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះ លោក **ឆុក សាន** មេភូមិបឹងឈូក ដែលជាអ្នកពាក់ព័ន្ធក្នុងការបោះឆ្នោតបានបំភ្លឺថា ក្នុងការសម្អាតបញ្ជីឈ្មោះ ប្រធានភូមិ និង មេ ៥០ខ្នង បានរួមគ្នាស្រង់ឈ្មោះមនុស្សដែលមិនឃើញនៅក្នុងមូលដ្ឋាន ប៉ុន្តែមានឈ្មោះក្នុងបញ្ជី ។ បញ្ជីនេះបានផ្ញើទៅក្រុមប្រឹក្សាសង្កាត់ ដើម្បីពិនិត្យពិចារណា ប៉ុន្តែចៅសង្កាត់មិនបានបិទផ្សាយ ជាហេតុនាំឱ្យគ្មានអ្នកមកតវ៉ា
- យល់ឃើញថា ទឡ្ហីករណ៍ដែលលោក **លី សុទិដ្ឋា** បានផ្តល់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ពុំមានមូលដ្ឋានគតិយុត្តិច្បាស់លាស់ ដើម្បីសុំរក្សាឈ្មោះប្រជាពលរដ្ឋចំនួន ៣.២៤៤ នាក់ ក្នុងបញ្ជីបោះឆ្នោតដំបូង
- យល់ឃើញថា ទឡ្ហីករណ៍ដែលលើកឡើងដោយតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានមូលដ្ឋានខាងផ្លូវច្បាប់ ដែលយកជាការបាន

សម្រេច

មាត្រា ១. - ទទួលពាក្យបណ្តឹងរបស់លោក **លី សុទិដ្ឋា** ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

មាត្រា ២. - តម្កល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដែលសម្រេចបដិសេធសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់គីឡូម៉ែត្រលេខ៦ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ចោលជាអាសារបង់ និង លុបឈ្មោះអ្នកបោះឆ្នោត ចំនួន ៣.២៤៤ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងសង្កាត់គីឡូម៉ែត្រលេខ៦ ទុកជាបានការពេញទាំងមូល ។

មាត្រា ៣. - សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០០៧ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ជ.ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ .ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៣០០ លានរៀល (បីរយលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៥ (ឧបត្ថម្ភកធន និងជំនួយសង្គម) របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាខេត្តកំពង់ឆ្នាំង នៃក្រសួងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ,ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក ,ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១៥១.០០០.០០០ រៀល (មួយរយហាសិបមួយលានរៀលគត់) ពីជំពូក ៦១ (សេវាខាងក្រៅ) ចំនួន៤១.៤០០.០០០ រៀល (សែសិបមួយលានបួនរយពាន់រៀលគត់) ជំពូក៦២ (សេវាខាងក្រៅផ្សេងៗ) ចំនួន ៩៣.៦០០.០០០រៀល (កៅសិបបីលានប្រាំមួយរយពាន់រៀលគត់) និងជំពូក៦៥ (ឧបត្ថម្ភកធន និង ជំនួយសង្គម) ចំនួន ១៦.០០០.០០០ រៀល (ដប់ប្រាំមួយលានរៀលគត់) មកជំពូក ៦០ (ការទិញ) ជូនក្រសួងមហាផ្ទៃ-ផ្នែករដ្ឋបាលទូទៅ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីផ្តល់ជូនក្រសួងមហាផ្ទៃ-ផ្នែករដ្ឋបាលទូទៅ សំរាប់ទិញប្រេងឥន្ធនៈបន្ថែមត្រីមាសទី៤ ឆ្នាំ ២០០៧ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៩៣៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

ៜ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូន មន្ត្រីរាជការ នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្តពោធិ៍សាត់ ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចនាឆ្នាំកន្លងមក ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

-លោក ញឹក សារ៉េត ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្តពោធិ៍សាត់

ខ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

-លោក អាំ សំអាត អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្តពោធិ៍សាត់

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង អភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ឆ្នាំ ២០០៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ..៩៣៦..អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូន មន្ត្រីរាជការ នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្តពោធិ៍សាត់ ចំនួន ១៩ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច នាឆ្នាំកន្លងមក ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសការងារ :

១-លោក	ម៉ៅ សុខុម	អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
២-លោក	ចិន រ៉ាន់	ប្រធានការិយាល័យ រដ្ឋបាល និងបុគ្គលិក
៣-លោក	នាយ ប៊ុនរិទ្ធ	ប្រធានការិយាល័យ ហិរញ្ញវត្ថុ និងផែនការ
៤-លោក	តុំ សំអុល	អនុប្រធានការិយាល័យ ហិរញ្ញវត្ថុ និងផែនការ
៥-លោកស្រី កើត	សុខវ៉ាន	ប្រធានការិយាល័យ សអយ ស្រុកល្វៀង
៦-លោក	សេង ពុយ	ប្រធានការិយាល័យ សអយ ស្រុកភ្នំក្រវ៉ាញ
៧-លោក	ហ៊ិង ជុំគ	ប្រធានការិយាល័យ សអយ ស្រុកវាលវែង

ខ-មេដាយប្រាក់ការងារ :

១-លោក	យឹម ដេត	ប្រធានការិយាល័យ អតីតយុទ្ធជន
២-លោក	សុខ គង់	ប្រធានការិយាល័យ សុខុមាលភាពសង្គម
៣-លោក	សិទ្ធ សិទ្ធី	អនុប្រធានការិយាល័យ រដ្ឋបាល និង បុគ្គលិក
៤-លោក	ជួន គោវិន្ទ	អនុប្រធានការិយាល័យ ហិរញ្ញវត្ថុ និងផែនការ
៥-លោក	ឃួន ទៃឃាត់	អនុប្រធានការិយាល័យ អតីតយុទ្ធជន
៦-លោក	អៀង ឃុង	អនុប្រធានការិយាល័យ អតីតយុទ្ធជន

គ-មេដាយសីទ្ធការងារ :

១-លោក រិន ណារិទ្ធ អនុប្រធានការិយាល័យ សុខុមាលភាពសង្គម
២-លោកស្រី ហ៊ុន បៀងចន្ទ មន្ត្រីការិយាល័យ ហិរញ្ញវត្ថុ និង ផែនការ
៣-លោក ចាន់ សុខា មន្ត្រីការិយាល័យ សអយ ស្រុកក្រគរ
៤-លោក ម៉ែន ផាត មន្ត្រីការិយាល័យ សអយ ស្រុកភ្នំក្រវាញ
៥-លោក គង់ ម៉ុនថន មន្ត្រីការិយាល័យ សអយ ស្រុកបាកាន
៦-លោក ម៉ៅ សុធី មន្ត្រីការិយាល័យ សអយ ស្រុកសំពៅមាស

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង អភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៧៣៧អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជនជាតិ **NEW ZEALAND** ចំនួន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ និង បំពាក់សម្ភារីមកំប្លេ នៅវត្តជោគជ័យ ស្ថិតក្នុងឃុំបាបោង ស្រុកពាមរក៍ ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម :-

១-Mr. JIM BLAKIE ថវិកា ចំនួន ២០.០០០ ដុល្លារ

២-Mrs .YUTH BLAKIE ថវិកា ចំនួន ១៤.៥០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៣៨ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយសហមេត្រី

ខាងក្រោម

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក **Yasunori ARAKI** ជំនាញការជប៉ុនប្រចាំនាយកដ្ឋានផែនការ និងស្ថិតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការ ជួយអភិវឌ្ឍន៍ វិស័យកសិកម្ម នៅព្រះរាជាណាចក្រកម្ពុជា សម្រេចបានលទ្ធផលយ៉ាងល្អប្រសើរ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៩៣៩...អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងផែនការ

សម្រេច

មាត្រា១: ត្រូវបានប្រគល់ភារកិច្ចជូនលោក **ឈន់ គឹមឈាង** ឱ្យបំពេញមុខងារជាអគ្គាធិការរង នៃអគ្គាធិការដ្ឋានក្រសួងផែនការ ។

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៤០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងផែនការ

សម្រេច

មាត្រា១: ត្រូវបានប្រគល់ភារកិច្ចជូនលោក **ថូ ទណ្ឌា** ឱ្យបំពេញមុខងារជាអធិការ នៃអគ្គាធិការដ្ឋាន ក្រសួងផែនការ ។

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

សម្រេច

មាត្រា ១.-

តែងតាំង ក្រុមប្រឹក្សាភិបាលមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ "**ម.អ.ជ.**" ដែលមានសមាសភាព ដូចខាងក្រោម :

១-ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធាន

២-ឯកឧត្តម **ស៊ីម សុន** រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ អនុប្រធាន

៣-ឯកឧត្តម **សួន ម៉េងសា** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៤-ឯកឧត្តម **ទី នរិន្ទ** ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា សមាជិក

៥-លោក **សេង ស៊ីន** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៦-លោក **សរ តីនីរ៉ា** តំណាង ក្រសួងមហាផ្ទៃ សមាជិក

៧-លោកស្រី Maria Karla Quizon តំណាងដៃគូអភិវឌ្ឍន៍ សមាជិក

៨-លោក **អ៊ែនឌី គាំង** (Mr. Andy Kun) តំណាងសមាគមធនាគារកម្ពុជា សមាជិក

៩-លោក **គង់ ពុទ្ធី** តំណាងអ្នកមានអាជ្ញាប័ណ្ណធ្វើសេវាកម្មអគ្គិសនី ដែលបានចូលរួមក្នុងគំរោងអភិវឌ្ឍន៍អគ្គិសនីជនបទ សមាជិក

១០-លោក **ស៊ាន ចាន់** តំណាងអង្គការក្រៅរដ្ឋាភិបាលដែលបានចូលរួម ក្នុងគំរោងអភិវឌ្ឍន៍អគ្គិសនីជនបទ សមាជិក

១១-លោក **គីម សឿន** តំណាងអ្នកប្រើប្រាស់អគ្គិសនីជនបទ សមាជិក

មាត្រា ២.-

ភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលមានជាអាទិ៍ :

១. អនុម័តគោលនយោបាយ និងនីតិវិធីប្រចាំឆ្នាំក្នុងការប្រើប្រាស់មូលនិធិ "**ម.អ.ជ.**"

២. ជ្រើសរើសនាយកប្រតិបត្តិនៃលេខាធិការដ្ឋាន "**ម.អ.ជ.**"

៣. អនុម័តរចនាសម្ព័ន្ធអង្គការចាត់តាំង គោលនយោបាយបុគ្គលិក បទបញ្ជាផ្ទៃក្នុងរបស់ "**ម.អ.ជ.**"

៤. តាមដានពិនិត្យលើការគ្រប់គ្រង កិច្ចប្រតិបត្តិការរបស់លេខាធិការដ្ឋាន "**ម.អ.ជ.**"

៥. ជ្រើសរើសភ្នាក់ងារទូទាត់របស់ "ម.ស.ជ."

៦. រៀបចំលក្ខខ័ណ្ឌតិក ៈសំរាប់ការរៀបចំ និងការប្រព្រឹត្តទៅនៃ "ម.ស.ជ."។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាជ្ញាធរអគ្គិសនីកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ២០០៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤

ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
